# ឃ្លាំមើលសភា និង តំណាងរាស្ត្រ

របាយការណ៍ឆ្នាំទី១ លេខ២ នីតិកាលទី ៤ ប្រចាំខែ វិច្ឆិកា ឆ្នាំ ២០០៨


## អ្នកតំណាងរាស្ត្រមួយចំនួនមិនអាចបំពេញតួនាទីរបស់ខ្លួនបាន

អ្នកតំណាងរាស្ត្រគណបក្សជំទាស់ដូចជាគណបក្ស **សម រង្ស៊ី** និង**សិទ្ធិមនុស្ស** បានលើកឡើងពីការលំបាករបស់ខ្លួនក្នុងការបំពេញតួនាទី ក្នុងការត្រួតពិនិត្យមើលសេចក្តីព្រាងច្បាប់ ឬ/និងជាភាពតំណាងរបស់គណបក្ស និងមណ្ឌលរបស់ខ្លួន ដោយសារតែមិនបានទទួលបានព័ត៌មានទាក់ទិននឹងដំណើរការសភា និងការពិភាក្សាសេចក្តីព្រាងច្បាប់/ស្នើច្បាប់នានា ដោយសារតែគ្មានតំណាងរាស្ត្រណាមួយក្នុងគណបក្សរបស់ខ្លួនជា សមាជិកគណៈ-កម្មការជំនាញរបស់រដ្ឋសភា និងការបង្កើតក្រុមតំណាងរាស្ត្រដែលតម្រូវឱ្យមានចំនួន ១០ អ្នកឡើងទៅ។

អ្នកតំណាងរាស្ត្រ **យឹម សុវណ្ណ** មណ្ឌលភ្នំពេញមកពីគណបក្ស សមរង្ស៊ី និងធ្លាប់ជាប្រធានគណៈកម្មការជំនាញទី ៤ នៃរដ្ឋសភានីតិកាលទី ៣ ទទួលបន្ទុកមហាផ្ទៃ អង្កេត បោសសំអាត និងមុខងារសាធារណៈបានចាត់ទុករដ្ឋសភាក្នុងនីតិកាលនេះស្ទើរតែជា *"របបផ្តាច់ការក្នុងការផ្តល់ព័ត៌មាន"*។

អ្នកតំណាងរាស្ត្ររូបនេះបានថ្លែងថា ការគ្មានវត្តមាននៅក្នុងគណៈកម្មការជំនាញ ឬអចិន្ត្រៃយ៍ គឺមានន័យថា តំណាងរាស្ត្រគឺចាំតែចូលប្រជុំពេញអង្គតែប៉ុណ្ណោះ។ អ្នកតំណាងរាស្ត្រ **យឹម សុវណ្ណ** បានបន្តទៀតថា *"កាលយើងនៅក្នុងគណៈកម្មការ គឺយើងទទួលបានព័ត៌មានច្រើនទាក់ទងនឹងសេចក្តីព្រាងច្បាប់ ឬសម័យប្រជុំនានា ហើយយើងអាចមានពេលច្រើនដើម្បីសិក្សា និងកែប្រែសេចក្តីព្រាងច្បាប់ និងរបៀបវារៈនានាដើម្បីផ្តល់អនុសាសន៍ និងពន្លឿនដល់កិច្ចប្រជុំសភាពេញអង្គ...តែឥឡូវគឺ ព័ត៌មានអត់មានទេ"*។

អ្នកតំណាងរាស្ត្រ **យ៉ែម បុញ្ញឫទ្ធិ** មកពីគណបក្ស សិទ្ធិមនុស្ស បានបង្ហាញពីការលំបាកដូចគ្នានេះដែរ។ អ្នកតំណាងរាស្ត្ររូបនេះបានឱ្យដឹងថា *"យើងអត់មាននៅក្នុងគណៈកម្មការជំនាញរបស់សភាទេ។ យើងមិនបានទទួលបានព័ត៌មានពីសេចក្តីព្រាងច្បាប់ ឬរបៀបវារៈនានាពេលចូលគណៈកម្មការជំនាញមួយៗរបស់សភានោះទេ ហើយវាបង្កលក្ខណៈលំបាកដល់តំណាងរាស្ត្រយើង គឺពេលដែលយើងទទួលបានសេចក្តីព្រាងច្បាប់នោះគឺវាកៀកទៅនឹងថ្ងៃប្រជុំពេញអង្គទៅហើយ ហើយការគិតគូរ រកឯកសារទាំងប៉ុន្មានគឺហាក់ធ្វើដោយប្រញាប់ប្រញាល់ពេក។ ដូចជាច្បាប់ថវិកា ២០០៩ គឺខ្ញុំទទួលបានពេលខ្ញុំចូលរួមសិក្ខាសាលា..."*។

តំណាងរាស្ត្រប្រឆាំងទាំងពីរគណបក្សនេះ បានទទួលស្គាល់ថា ការមិនអាចទទួលបានព័ត៌មានពីសេចក្តីព្រាងច្បាប់នានាពេលចូលគណៈកម្មការជំនាញរដ្ឋសភា និងធ្វើឱ្យពួកខ្លួនមិនមានពេលគ្រប់គ្រាន់ដើម្បីសិក្សាសេចក្តីព្រាងច្បាប់ទាំងនោះដែលធ្វើឱ្យខ្លួនជួបឧបសគ្គក្នុងការពិភាក្សា ឬផ្តល់អនុសាសន៍ទៅរាជរដ្ឋាភិបាល។

ទោះបីយ៉ាងណា អ្នកតំណាងរាស្ត្រទាំងពីរបានឱ្យដឹងថា គណបក្សរបស់ខ្លួនមិនមានផែនការដើម្បីស្នើសុំបញ្ចូលសមាជិកសភារបស់ខ្លួនចូលក្នុងគណៈកម្មការជំនាញរបស់រដ្ឋសភានោះទេ បើសិនជាមិនមានការកែលម្អបទបញ្ជាផ្ទៃក្នុងដើម្បីទទួលស្គាល់សិទ្ធិ និងតួនាទីរបស់តំណាងរាស្ត្រគណបក្សប្រឆាំងដែលអាចចូលរួមក្នុងការដឹកនាំគណៈកម្មការសភាខ្លះៗដែរនោះទេ។

ការស្រាវជ្រាវជាច្រើនបានផ្តល់យោបល់ថា *ប្រទេសប្រកាន់លទ្ធិប្រជាធិបតេយ្យ ពួកគេផ្តើមធ្វើឱ្យមាននិត្យានុកូលភាព និងការទទួលស្គាល់ខាងផ្លូវច្បាប់ចំពោះសិទ្ធិ និងតួនាទីគណបក្សប្រឆាំងក្នុងសភា"*។

## <u>ការកំណត់ក្រុមឡើងនិយាយរបស់សភា ជាឧបសគ្គរារាំងការបញ្ចេញមតិរបស់គណបក្សតូច</u>

បទបញ្ជាផ្ទៃក្នុងរដ្ឋសភាដែលតម្រូវឱ្យសមាជិកសភាត្រូវបង្កើតក្រុម ទើបអាចមានសិទ្ធិបញ្ចេញមតិនៅសម័យប្រជុំសភាពេញអង្គ នឹងធ្វើឱ្យតំណាងរាស្ត្រគណបក្សតូចៗមិនអាចការពារគោលនយោបាយ ទស្សនៈ និងឧត្តមគតិរបស់ខ្លួនដែលបានសន្យាជាមួយម្ចាស់ឆ្នោតបានទេ។

គណបក្សចំនួន ៣ គឺគណបក្ស **សិទ្ធិមនុស្ស** គណបក្ស **នរោត្តមរណឫទ្ធិ** និងគណបក្ស **ហ្វ៊ុនស៊ិនប៉ិច** មិនអាចបង្កើតក្រុមឡើងបញ្ចេញមតិដោយខ្លួនឯងនោះទេ ផ្ទុយទៅវិញតំណាងរាស្ត្រគណបក្សទាំងនេះ អាចទៅសុំចូលរួមក្នុងក្រុមរបស់គណបក្សផ្សេងៗ ដែលពេលខ្លះមាននិន្នាការនយោបាយខុសពីគណបក្សរបស់ខ្លួន។

ប្រធានគណបក្ស សិទ្ធិមនុស្ស អ្នកតំណាងរាស្ត្រ **កឹម សុខា** ដែលមិនមានឈ្មោះនៅក្នុងក្រុមបញ្ចេញមតិណាមួយទេនោះ ធ្លាប់បានបង្ហាញកង្វល់របស់ខ្លួនថា *"ការបង្កើតក្រុមរបស់សមាជិកសភា សម្រាប់គណបក្សមានកៅអីតិចជាង១០នៅក្នុងសភាមិនអាចមានគ្នាគ្រប់ចំនួននោះព្រោះពិបាកចូលជាមួយគណបក្សផ្សេងទៀត ដែលមានគោលនយោបាយខុសគ្នា"*។

បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាបានកំណត់ថា *"ក្រុមឡើងបញ្ចេញមតិនីមួយៗត្រូវមានសមាជិកយ៉ាងតិច ១០រូប...គណបក្សនយោបាយដែលមានអាសនៈតិចជាង ១០ ត្រូវជ្រើសរើសក្រុមណាមួយដែលខ្លួនពេញចិត្តនៅជាមួយ...ក្រុមនីមួយៗអាចបញ្ចេញមតិបានត្រឹមតែ ២០នាទីប៉ុណ្ណោះ"*។

បទបញ្ជាផ្ទៃក្នុងនេះ មិនបង្កឱ្យអ្នកតំណាងរាស្ត្រនៃគណបក្សតូចមានសម្លេងរបស់ខ្លួន នៅក្នុងសភានោះទេ ខណៈដែលគំនិតដើមនៃការបង្កើតក្រុមរបស់សភា គឺផ្តល់ឱកាសឱ្យគណបក្សនីមួយៗមានក្រុមរបស់ខ្លួន។

ដូចនេះ បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាគួរធ្វើវិសោធនកម្មបន្តិចថា *គណបក្សណាមួយដែលមានអាសនៈតិចជាង ១០ រូប អាចបង្កើតក្រុមមួយបាន*។ យន្តការនេះនឹងធ្វើឱ្យមានការគោរពមតិភាគតិច ព្រោះថាអ្នកតំណាងរាស្ត្រអាចបញ្ចេញមតិបានលុះត្រាតែខ្លួនជាសមាជិកនៃក្រុមណាមួយ។

## <u>តំណាងរាស្ត្រប្រឆាំងនៅតែបន្តស្នើកែប្រែបទបញ្ជាផ្ទៃក្នុងរដ្ឋសភា</u>

តំណាងរាស្ត្រគណបក្ស **សមរង្ស៊ី** បានឱ្យដឹងនៅចុងខែ វិច្ឆិកា ថាក្រុមតំណាងរាស្ត្ររបស់ខ្លួននៅតែបន្តស្នើសុំកែប្រែបទបញ្ជាផ្ទៃក្នុងរដ្ឋសភា បើទោះជាតំណាងរាស្ត្រគណបក្សកាន់អំណាចថា ការធ្វើវិសោធនកម្មនេះមិនអាចទៅរួចក៏ដោយ។

អ្នកតំណាងរាស្ត្រ **មូរ សុខហួរ** មណ្ឌលកំពតមកពីគណបក្ស សមរង្ស៊ី បានថ្លែងថា ការសម្របសម្រួលផ្នែកនយោបាយគឺជាកត្តាចម្បងក្នុងការធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ដើម្បីធានាតួនាទីរបស់គណបក្សប្រឆាំងក្នុង រដ្ឋសភា។ អ្នកតំណាងរាស្ត្ររូបនេះ បានថ្លែងថា *"គណបក្សសមរង្ស៊ី មានការសង្ឃឹមថា នឹងមានការសម្របសម្រួលខាងនយោបាយពីខាងគណបក្សកាន់អំណាច។ អ្វីដែលខាងប្រឆាំងកំពុងធ្វើគឺមិនមែនចរចាយកអំណាច និងតំណែងនោះទេ។"*

តំណាងរាស្ត្រគណបក្ស សមរង្ស៊ី កាលពីខែ តុលា ធ្លាប់បានស្នើធ្វើវិសោធនកម្មនេះម្តងហើយដែរ តែត្រូវបានគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបដិសេធចោលដោយចំនួនតំណាងរាស្ត្រស្នើសុំមិនគ្រប់ចំនួន ៣១ រូប តាមនីតិវិធី។

កាលពីថ្ងៃ១៧ វិច្ឆិកា អនុប្រធានគណបក្សប្រជាជនកម្ពុជា និងជានាយករដ្ឋមន្ត្រី សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានប្រកាសជាសាធារណៈថា នឹងគ្មានការកែប្រែបទបញ្ជាផ្ទៃក្នុងនោះទេ។ សម្តេច បានលើកឡើងថា *"ការកែប្រែនឹងហួសហេតុ មិនអាចទទួលយកបាន ដោយកែដល់ទៅ ២៦ លើ ៨២ ចំនុច ហើយសុទ្ធតែកន្លែងខ្លាញ់ មិនអាចឱ្យបានទេ។"*

ទោះបីយ៉ាងណា ប្រធានគណៈកម្មាធិការនាយក ខុមហ្វ្រែល លោក ធន សារាយ បានមានប្រសាសន៍ថា ការបែងចែកអំណាចនៅក្នុងសភារវាងគណបក្សជាប់ឆ្នោតទាំងអស់ គឺជាគ្រឹះសម្រាប់លទ្ធិប្រជាធិបតេយ្យៈ *"គោលការណ៍ប្រជាធិបតេយ្យ គឺគណបក្សដែលមានសម្លេងតិច គឺគួរតែមានសម្លេងនៅក្នុងសភាឱ្យបានច្រើនដើម្បីឱ្យមានការត្រួតពិនិត្យអំណាច ពីព្រោះសភាមិនមែនជាអំណាចដែលអនុវត្តទេ គឺជាអំណាចតាក់តែងច្បាប់ ហើយនិងឃ្លាំមើលអ្នកអនុវត្តហ្នឹងប្រព្រឹត្តត្រូវ ឬមិនត្រូវយ៉ាងម៉េច។"*

ខ្លឹមសារសំខាន់ៗនៃវិសោធនកម្មលើបទបញ្ជាផ្ទៃក្នុងនេះរួមមាន ការបែងចែកអំណាចប្រធានរដ្ឋសភាទៅតាមការស្នើរបស់គណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា អនុប្រធានទីមួយតាមការស្នើរបស់គណបក្សមានអាសនច្រើនលំដាប់ទី ២ និងអនុប្រធានទី២ តាមការស្នើរបស់គណបក្សច្រើនលំដាប់ទី៣ ហើយក៏មានការបែងចែកអំណាចក្នុងប្រធានគណៈកម្មការជំនាញខ្លះៗ និងមានខ្ទង់ថវិកាសំរាប់គណបក្ស ប្រឆាំងផងដែរ ។

## គ.ជ.ប គ្រោងប្តឹងតំណាងរាស្ត្រគណបក្សប្រឆាំងទៅតុលាការ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានដាក់លិខិតទៅប្រធានរដ្ឋសភាស្នើកាត់ប្រាក់ខែអ្នកតំណាងរាស្ត្រ សម រង្ស៊ី ជាថ្នូរនឹងប្រាក់ពិន័យដែលអ្នកតំណាងរាស្ត្ររូបនេះបានជេរប្រមាថមេដឹកនាំកំពូលទាំងបីរបស់គណបក្សប្រជាជនកម្ពុជា តែមិនបានទទួលការឆ្លើយតបជាវិជ្ជមានពីរដ្ឋសភាព្រោះខុសនីតិវិធី ។

អ្នកតំណាងរាស្ត្រ **ជាម យៀប** ត្រូវបានដកស្រង់សំដីថា ពុំមានគោលការណ៍ណាតម្រូវឱ្យកាត់ប្រាក់បៀវត្សអ្នកតំណាងរាស្ត្រក្នុងករណីដូចនេះទេ។

អគ្គលេខាធិការ គ.ជ.ប ឯកឧត្តម **ទេព នីថា** បានមានប្រសាសន៍ថា *"រដ្ឋសភាមិនទាន់ឆ្លើយតបជាផ្លូវការទេប គ.ជ.ប ដកឯកសារមកវិញដើម្បីដាក់ទៅតុលាការ ព្រោះតុលាការជាជម្រើសចុងក្រោយ ហើយនឹងចាត់វិធានការតាមផ្លូវច្បាប់"*។ ឯកឧត្តម **ទេព នីថា** បានឱ្យដឹងថាក្នុងការបោះឆ្នោតឆ្នាំ ២០០៨នេះ គ.ជ.ប បានពិន័យមនុស្សចំនួន ៨នាក់ ហើយ៧នាក់បានបង់រួចហើយ ។

គ.ជ.ប មានគម្រោងប្តឹងអ្នកតំណាងរាស្ត្រគណបក្ស សមរង្ស៊ី ទៅកាន់តុលាការនាពេលដ៏ខ្លីខាង មុខនេះពីបទមិនព្រមបង់ប្រាក់ពិន័យ ។

ឯកឧត្តម **ទេព នីថា** បានមានប្រសាសន៍ប្រាប់ខុមប្រ៊ែលនៅចុងខែវិច្ឆិកាថា គ.ជ.ប កំពុងរៀបចំពាក្យបណ្តឹង និងឯកសារនានាដើម្បីដាក់ទៅតុលាការប្តឹងអ្នកតំណាងរាស្ត្រ **សម រង្ស៊ី** ពីបទមិនបង់ប្រាក់ផាកពិន័យ ដែលអ្នកតំណាងរាស្ត្ររូបនេះបានជេរប្រមាថមេដឹកនាំកំពូលទាំងបីរបស់គណបក្សប្រជាជនកម្ពុជាថាជា **ចោរលួចជាតិ** ក្នុងកំឡុងពេលឃោសនាបោះឆ្នោត ។

ខុមប្រ៊ែលមិនអាចសុំការបំភ្លឺពីឯកឧត្តម សម រង្ស៊ី បានទេ ព្រោះតែឯកឧត្តមនៅក្រៅប្រទេស តែជំនួយការ អ្នកតំណាងរាស្ត្រ សម រង្ស៊ី លោក **ស៊ុន ចាន់ធី** បានបញ្ជាក់ថា ការដែលអ្នកតំណាងរាស្ត្រ សម រង្ស៊ី មិនព្រមបង់ប្រាក់ពិន័យ ព្រោះតែពាក្យបណ្តឹងរបស់គណបក្សសមរង្ស៊ី ប្តឹងទៅ គ.ជ.ប ពីភាពមិនប្រក្រតីនានាទាក់ទិននឹងការបោះឆ្នោត មិនទាន់បានរកយុត្តិធម៌ឱ្យនៅឡើយទេ។

អ្នកតំណាងរាស្ត្រ សម រង្ស៊ី ត្រូវបានពិន័យពីបទជេរប្រមាថថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជាក្នុងពេលឃោសនាបោះឆ្នោតអាណត្តិទី៤ កន្លងទៅៗនេះ ហើយត្រូវបានគណបក្សប្រជាជនកម្ពុជាដាក់បណ្តឹងទៅ គ.ជ.ប ហើយត្រូវបាន គ.ជ.ប សម្រេចពិន័យជាប្រាក់ ១០ លានរៀល ឬស្មើនឹងប្រមាណ ២.៥០០ ដុល្លាអាមេរិក ។ អ្នកតំណាងរាស្ត្ររូបនេះ ក៏បានព្រមានថា នឹងដាក់ពាក្យប្តឹងទៅ គ.ជ.ប វិញ ពីបទក្លែងឯកសារទម្រង់ ១០១៨។

## អ្នកតំណាងរាស្ត្របានពិភាក្សាច្រើនពីថវិកាជាតិ ពិសេសវិស័យការពារជាតិ

អ្នកតំណាងរាស្ត្រគណបក្សកាន់អំណាច និងគណបក្សប្រឆាំងបានគាំទ្រទៅលើការចំណាយថវិកាជាតិឆ្នាំ ២០០៩ ទៅលើអាទិភាពវិស័យការពារជាតិ តែតម្រូវឱ្យមានកំណែទម្រង់ និងតម្លាភាពក្នុងការចំណាយ ។

អ្នកតំណាងរាស្ត្រ **ជាម យៀប** មកពីគណបក្សប្រជាជនកម្ពុជា និងជាប្រធានគណៈកម្មការ សេដ្ឋកិច្ចនៃរដ្ឋសភាបានថ្លែងថា អាទិភាពចម្បងគឺវិស័យការពារជាតិ។ អ្នកតំណាងរាស្ត្ររូបនេះបានថ្លែងនៅថ្ងៃទី ២០ វិច្ឆិកា ក្នុងសិក្ខាសាលាពិភាក្សាសេចក្តីព្រាងច្បាប់ថវិកា ២០០៩ ថា *"អាទិភាពចម្បងគឺ វិស័យការពារជាតិ ដែលផ្តោតសំខាន់លើកំណែទម្រង់វិស័យការពារជាតិ និងកាតព្វកិច្ចយោធាដើម្បីផ្លាស់ប្តូរទាហានវ័យចំណាស់ៗ និងសព្វាវុធហួសសម័យ ដោយលុបបំបាត់ ការចំណាយមិនចាំបាច់ [នៅក្នុងស្ថាប័នរដ្ឋ]"* ។

អ្នកតំណាងរាស្ត្រគណបក្សជំទាស់ ហួរ វ៉ាន់ បានគាំទ្រការផ្តល់អាទិភាពទៅលើវិស័យការពារជាតិដែរ តែតម្រូវឱ្យការចំណាយមានតម្លាភាព និងប្រសិទ្ធភាពទៅលើវិស័យការពារជាតិ។

អ្នកតំណាងរាស្ត្ររូបនេះបានថ្លែងប្រាប់ខុមហ្វ្រែលថា *"វាមិនជាបញ្ហាទេ តែសំខាន់ឱ្យតែបានទៅដល់ដៃកងទ័ព កុំឱ្យពួកគាត់មានការខ្វះខាត សូម្បីតែស្បែកជើងក៏មិនមានគ្រប់គ្រាន់ដែរ"*។

ទោះបីយ៉ាងណា អ្នកតំណាងរាស្ត្ររូបនេះ មិនជឿជាក់ទៅលើការចំណាយនេះទេ ព្រោះរាល់ការចំណាយទាំងឡាយមិនដែលបានសួរដេញដោលក្នុងរដ្ឋសភាទេ ហើយការទូទាត់ថវិកាឆ្នាំកន្លង១មកដែលចំណាយរួចហើយក៏មិនទាន់ពេលវេលាដែរ។

បើទោះបីជាយ៉ាងនេះក្តីអ្នកតំណាងរាស្ត្រ **ញ៉ែម បុញ្ញឫទ្ធិ** មណ្ឌលព្រៃវែងមកពីគណបក្សសិទ្ធិមនុស្ស បានរិះគន់ទៅលើការបែងចែកថវិកាសម្រាប់វិស័យកសិកម្ម ថា: *"វាមិនសូវសមហេតុផលលើប្រទេសមួយដែលកំពុងកាត់បន្ថយលើភាពក្រីក្រ គឺត្រូវលើកស្ទួយប្រជាកសិករដែលមានទៅដល់ ៨០% តែបែរជាផ្តល់ឱ្យក្រសួងមហាផ្ទៃ និងក្រសួងការពាជាតិ យ៉ាងច្រើនជាងទៅវិញ"*។

គួរបញ្ជាក់ថានៅថ្ងៃទី ២០ ខែវិច្ឆិកា កន្លងទៅនេះ រដ្ឋសភាបានធ្វើសិក្ខាសាលាមួយដើម្បីពិភាក្សាលើច្បាប់ថវិកាជាតិ២០០៩ នេះ ជាមួយនឹងរាជរដ្ឋាភិបាល ដែលមានអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានចូលរួមផងដែរ។ ហើយរដ្ឋសភានឹងបើកសម័យប្រជុំពេញអង្គរបស់ខ្លួនដើម្បីពិភាក្សាសេចក្តីព្រាងច្បាប់នេះនៅដើមខែធ្នូ។

## រដ្ឋសភា មិនទាន់បានទទួលការបំភ្លឺពីរាជរដ្ឋាភិបាលជុំវិញការឈ្លានពានរបស់ថៃ

អ្នកតំណាងរាស្ត្រ សុន ឆ័យ បានឱ្យខុមហ្វ្រែលដឹងថា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន មិនទាន់បានឆ្លើយតបជាផ្លូវការ ជុំវិញការដែលរដ្ឋសភា បានស្នើសម្តេចនាយករដ្ឋមន្ត្រីមកបំភ្លឺនៅសភា ជុំវិញការឈ្លានពានរបស់ប្រទេសថៃ មកលើប្រទេសកម្ពុជានៅឡើយទេ។

ទោះបីយ៉ាងណា អ្នកតំណាងរាស្ត្ររូបនេះ បានឱ្យដឹងថា ខ្លួននឹងយកបញ្ហានេះមកនិយាយម្តងទៀត នៅពេលសភាប្រជុំពេញអង្គពិភាក្សាទៅលើសេចក្តីព្រាងច្បាប់។

អ្នកតំណាងរាស្ត្រ សុន ឆ័យ កាលពីចុងខែវិច្ឆិកា បានដាក់លិខិតមួយច្បាប់ តាមរយៈប្រធានរដ្ឋសភា ដោយស្នើឱ្យសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន មកបំភ្លឺ នៅរដ្ឋសភាទៅលើគោលនយោបាយរបស់រាជរដ្ឋាភិបាលលើការដោះស្រាយការឈ្លានពានទឹកដីពីប្រទេសថៃ ដែលអូសបន្លាយរាប់ខែ។

ទោះបីយ៉ាងណា អ្នកនាំពាក្យរាជរដ្ឋាភិបាល និងជារដ្ឋមន្ត្រីក្រសួងព័ត៌មាន ឯកឧត្តម ខៀវ កាញារីទ្ធ បានចាត់ទុកការហៅរាជរដ្ឋាភិបាលទៅបំភ្លឺនោះ គឺជាការខាតពេលវេលា: *"គាត់មិនដែលតាមដានព័ត៌មានអីទេមើលទៅ...អ្នកម៉ូតូឌុបក៏ដឹងថារដ្ឋាភិបាលធ្វើការដល់ណាហើយដែរឥឡូវ។"*

ក្នុងនីតិកាលទី ៣ កន្លងទៅ ខុមហ្វ្រែល សង្កេតឃើញថា មានលិខិតរបស់តំណាងរាស្ត្រ គណបក្សជំទាស់យ៉ាងតិចចំនួន ២៣ លិខិត បានដាក់ជូនរាជរដ្ឋាភិបាលដើម្បីស្នើសុំមកបំភ្លឺជុំវិញបញ្ហានានាទាក់ទងនឹងការងាររបស់រាជរដ្ឋាភិបាលនៅសម័យប្រជុំពេញអង្គរដ្ឋសភា ក៏ប៉ុន្តែតំណាងរាជរដ្ឋាភិបាលចូលមកបំភ្លឺតែ ៤ លើកប៉ុណ្ណោះ។

**************************************